00339228

E73

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 08 / JUN / 2009
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA Huy

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| | |
|---|---|
| សំណុំរឿងលេខ: | ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ |
| ថ្ងៃដាក់: | ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៩ |
| ភាគីអ្នកដាក់: | ការិយាល័យសហព្រះរាជអាជ្ញា |
| ភាសាដើម: | អង់គ្លេស |
| ប្រភេទឯកសារដែលស្នើឡើង: | សាធារណៈ |

---

## សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យអនុវត្តសហកម្មខ្មែរក្រហមរួម

---

**អ្នកដាក់ឯកសារ:**

**ការិយាល័យសហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Robert PETIT
លោក យ៉េត ចរិយា
លោក William SMITH
លោក Anees AHMED
លោក សេង ប៊ុនឃាង
លោក Stuart FORD

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង៖**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ធូ មណី

**ជនជាប់ចោទឈ្មោះ៖**
កាំង ហ្គេកអ៊ាវ *ហៅ* "ឌុច"

**មេធាវីរបស់ជនជាប់ចោទ៖**
លោក ការ សាវុត្ថ
លោក François ROUX

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 16 / 06 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

## ១. សេចក្ដីផ្ដើម

១. វិធាន៩២ នៃវិធានផ្ទៃក្នុងចែងថា ភាគីអាចដាក់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ខ្លួនទៅអង្គជំនុំជម្រះសាលាដំបូង ។ វិធាន៩៨.២ ចែងថា អង្គជំនុំជម្រះសាលាដំបូងអាចផ្លាស់ប្ដូរការកំណត់បទចោទ ដែលបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ អនុលោមតាមវិធាន ៩២ និងវិធាន ៩៨.២ សហព្រះរាជអាជ្ញា សូមស្នើដល់អង្គជំនុំជម្រះសាលាដំបូង អនុវត្តសហកម្មឧក្រិដ្ឋកម្មរួម ជាទម្រង់មួយនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ចំពោះតួនាទីរបស់ជនជាប់ចោទ នៅក្នុងឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តឡើងនៅមន្ទីរស-២១ ។

២. សហព្រះរាជអាជ្ញា សន្និដ្ឋានថា ទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលគេស្គាល់ថា សហកម្មឧក្រិដ្ឋកម្មរួម (JCE) គឺជាទម្រង់មួយនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌដែលអាចអនុវត្តបាន និងអាចទទួលយកបាន នៅក្នុងករណីប្រឆាំងនឹង កាំង ហ្គេកអ៊ាវ *ហៅ* ឌុច ដោយសារ (១) មានភស្តុតាងគ្រប់គ្រាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីសន្និដ្ឋានជាចុងក្រោយថា ឌុច បានប្រព្រឹត្តបទឧក្រិដ្ឋដូចដែលបានចោទប្រកាន់ តាមរយៈការចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម, (២) សហកម្មឧក្រិដ្ឋកម្មរួម ត្រូវបានធ្វើការថ្លែងសំអាងយ៉ាងត្រឹមត្រូវ ដោយសហព្រះរាជអាជ្ញា នៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន និង (៣) សហកម្មឧក្រិដ្ឋកម្មរួម ពិតជាមាននៅក្នុងទម្លាប់អន្តរជាតិតាំងពីទសវត្សរ៍ឆ្នាំ១៩៤០ និងនៅជាធរមាន នៅចំពោះមុខអ.វ.ត.ក ។

## ២. ប្រវត្តិនីតិវិធី

៣. នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ភាគីថា ការស៊ើបសួរនៅក្នុងសំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿងលេខ ០០១") ត្រូវបានបញ្ចប់ ។ អនុលោមតាមវិធាន៦៦ សំណុំរឿងលេខ ០០១ ត្រូវបានបញ្ជូនមកឲ្យសហព្រះរាជអាជ្ញា ។ សហព្រះរាជអាជ្ញា បានដាក់ ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួនដែលមានចំណងជើងថា "វិធាន៦៦ ដីកាសន្និដ្ឋានស្ថាពរ ទាក់ទងនឹង កាំង ហ្គេកអ៊ាវ *ហៅ*

"ឌុច" នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៨ (ចាប់ពីនេះតទៅហៅថា "ដីកាសន្និដ្ឋានស្ថាពរ")[1] ។ សហមេធាវីការពារក្ដីរបស់ ឌុច បានដាក់សារណាតបរបស់ខ្លួនទៅនឹងដីកាសន្និដ្ឋានស្ថាពរនេះ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៨[2] ។ នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ ដោយធ្វើការចោទប្រកាន់ ឌុច (ចាប់ពីនេះតទៅហៅថា "ដីកាដំណោះស្រាយ" ឬ "ដីកាបញ្ជូនរឿងទៅជំនុំជម្រះ")[3] ។

៤. សហព្រះរាជអាជ្ញា បានដាក់សេចក្ដីជូនដំណឹងមួយអំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៨[4] ហើយបានដាក់សារណាបណ្ដឹងឧទ្ធរណ៍របស់ខ្លួន នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៨[5] ។ សហមេធាវីការពារក្ដីរបស់ ឌុច បានដាក់សារណាតបរបស់ខ្លួនទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨[6] ។ អ.ប.ជ បានចេញសេចក្ដីសម្រេចរបស់ខ្លួន ("ចាប់ពីនេះតទៅហៅថា "សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍") លើបណ្ដឹងឧទ្ធរណ៍នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ ដោយធ្វើការកែប្រែលើដីកាដំណោះស្រាយ ដោយបង្គាប់ឲ្យបន្តការឃុំខ្លួនបណ្ដោះអាសន្ន ឌុច និងបង្គាប់ឲ្យបញ្ជូន ឌុច ទៅជំនុំជម្រះ[7] ។

៥. អង្គជំនុំជម្រះសាលាដំបូង បានចាប់ផ្ដើមបើកសវនាការលើសំណុំរឿងលេខ ០០១ នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៨ ។ នៅក្នុងពេលសវនាការបឋម សហព្រះរាជអាជ្ញាបានជូនដំណឹងដល់អង្គ

---

[1] វិធាន៦៦ ដីកាសន្និដ្ឋានស្ថាពរទាក់ទងនឹងកាំង ហ្គេកអ៊ាវ *ហៅ* "ឌុច", ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨, D96 ("ដីកាសន្និដ្ឋានស្ថាពរ")។

[2] សារណាពីសំណាក់ក្រុមមេធាវីការពារក្ដីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា, ចុះថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០០៨, D96/1, ("សារណាតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ") ។

[3] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កាំង ហ្គេចអ៊ាវ ហៅ ឌុច, ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨, D99 ("ដីកាដំណោះស្រាយ") ។

[4] សៀវភៅចុះបញ្ជីបណ្ដឹងឧទ្ធរណ៍, ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៨, D99/3, ("សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍") ។

[5] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច", ចុះថ្ងៃទី០៥ កញ្ញា ឆ្នាំ២០០៨, *D99/3/3* ("សារណាបណ្ដឹងឧទ្ធរណ៍") ។

[6] ចម្លើយរបស់ក្រុមការពារក្ដីចំពោះបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាដំណោះស្រាយចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ ២០០៨, ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨, D99/3/8, ("ចម្លើយរបស់ក្រុមមេធាវីចំពោះបណ្ដឹងឧទ្ធរណ៍") ។

[7] អង្គបុរេជំនុំជម្រះ, "សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណី កាំង ហ្គេកអ៊ាវ ហៅ "ឌុច", ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨, D99/3/42 ("សាលដីកាលើបណ្ដឹងឧទ្ធរណ៍") ។

ជំនុំជម្រះសាលាដំបូងថា សហព្រះរាជអាជ្ញាសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង អនុវត្តលើទម្រង់នៃការទទួលខុសត្រូវដែលគេស្គាល់ថា សហកម្មឧក្រិដ្ឋកម្មរួម ចំពោះសកម្មភាពរបស់ ឌុច នៅមន្ទីរស-២១ និងថា សហព្រះរាជអាជ្ញានឹងដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរមួយទាក់ទិននឹងការអនុវត្តន៍សហកម្មឧក្រិដ្ឋរួម នៅក្នុងករណីប្រឆាំងនឹង ឌុច[8] ។

## ៣. សេចក្តីសង្ខេបនៃអំណះអំណាង

៦. នេះមិនមែនជាការតវ៉ាចំពោះសេចក្តីសម្រេចរបស់ អ.ប.ជ ទេ ។ ផ្ទុយទៅវិញ សំណើនេះ ("សំណើ") សុំឱ្យអង្គជំនុំជម្រះសាលាដំបូង ប្រើប្រាស់សិទ្ធិអំណាចដែលមានជាប់មកជាមួយស្របតាមវិធាន ៩៨.២ ដើម្បី "ផ្លាស់ប្តូរការកំណត់បទចោទ" ដែលបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីឱ្យបទចោទស៊ីគ្នាជាមួយនឹងភស្តុតាងដែលប្រមូលបាន នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ និងដែលបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[9] ។

៧. សាលដីការបស់ អ.ប.ជ ទាក់ទិននឹងការកំណត់បទចោទ មិនចងកាតព្វកិច្ចអង្គជំនុំជម្រះសាលាដំបូងទេ ។ ស្របគ្នានេះដែរ ទោះបីការពិតដែលថា អ.ប.ជ បានធ្វើការសម្រេចជាបឋមនៅលើការអនុវត្តន៍សហកម្មឧក្រិដ្ឋកម្មរួមក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូង មានសេរីភាពក្នុងការលើកនូវបញ្ហា និងការផ្លាស់ប្តូរការកំណត់បទចោទ ដោយផ្អែកទៅលើអង្គហេតុនានាដែលមាននៅក្នុង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងអង្គហេតុទាំងឡាយណា ដែលបានបង្ហាញក្នុងអំឡុងពេលនៃសវនាការជំនុំជម្រះ ។ ការបន្ថែមសហកម្មឧក្រិដ្ឋកម្មរួមជាទម្រង់មួយនៃការទទួលខុសត្រូវ គឺជាការសមស្រប ដោយសារ អ.ប.ជ មានការភាន់ច្រឡំក្នុងការសន្និដ្ឋានថា សហកម្មឧក្រិដ្ឋកម្មរួម មិនគួរត្រូវបានអនុវត្តទេ ។ ការបន្ថែមសហកម្មឧក្រិដ្ឋកម្មរួម នឹងមិនធ្វើឱ្យខូចដល់ការការពារខ្លួនរបស់ឌុច ទេ ពីព្រោះ អង្គហេតុទាំងអស់ដែលចាំបាច់សម្រាប់ធ្វើការកំណត់សម្រេចលើសហកម្មឧក្រិដ្ឋកម្មរួម គឺមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ រួច

---

[8] *សូមអាន* ប្រតិចារិកនៃនីតិវិធីសវនាការ ឌុច, ច្បាប់ផ្សាយជាសាធារណៈ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩, សំណុំរឿងលេខ: E1/3.1, ត្រង់ទំព័រទី ៧-៨ ។

[9] វិធាន ៩៨.២ នៃវិធានផ្ទៃក្នុង ។

00339232



ហើយៗ សហព្រះរាជអាជ្ញា ក៏ពេញចិត្តចំពោះគ្រប់ធាតុផ្សំទាំងអស់ ដែលចាំបាច់ដើម្បីធ្វើការថ្លែងសំអាងឲ្យត្រឹមត្រូវអំពីសហកម្មឧក្រិដ្ឋកម្មរួមនេះ ។ ជាងនេះទៀតសហកម្មឧក្រិដ្ឋកម្មរួមគឺចាំបាច់ត្រូវរៀបរាប់ឲ្យបានត្រឹមត្រូវពិតប្រាកដពីវិសាលភាពនៃអំពើព្រហ្មទណ្ឌរបស់ ឌុច ។

៨. ជាចុងក្រោយ គ្រប់ទម្រង់នៃសហកម្មឧក្រិដ្ឋកម្មរួមទាំងបី គឺអាចអនុវត្តបាននៅ អ.វ.ត.ក ។ សហកម្មឧក្រិដ្ឋកម្មរួម បានក្លាយជាផ្នែកមួយនៃទម្លាប់អន្តរជាតិ តាំងពីទសវត្សរ៍ ឆ្នាំ ១៩៤០ មកម្ល៉េះ ។ ការអនុវត្តន៍សហកម្មឧក្រិដ្ឋកម្មរួមអាចឲ្យគេរកបាន និងព្យាករណ៍បានថាស្ថិតក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ហើយមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក បានចែងយ៉ាងទូលំទូលាយគ្រប់គ្រាន់ ដើម្បីក្រសោបយកសហកម្មឧក្រិដ្ឋកម្មរួម ជាទម្រង់មួយនៃការទទួលខុសត្រូវ ។ ដោយហេតុនេះ អង្គជំនុំជម្រះសាលាដំបូង អាច និងគួរតែផ្លាស់ប្តូរការកំណត់បទចោទ ដោយផ្អែកទៅលើអង្គហេតុនានាដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីឲ្យឌុច អាចនឹងត្រូវបានគេរកឃើញថា មានការទទួលខុសត្រូវ ជាអ្នកចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម ។

## ៤. អំណះអំណាង

### ក. សំណើនេះមិនមែនជាការតវ៉ាចំពោះសេចក្តីសម្រេចរបស់ អ.ប.ជ ទេ

#### i. ជាទូទៅ

៩. សហព្រះរាជអាជ្ញាសន្និដ្ឋានថា ឌុច គឺជាផ្នែកស្នូលនៃសហកម្មឧក្រិដ្ឋកម្មរួមមួយ ដែលរួមមានទាំងអ្នកនៅក្រោមបង្គាប់របស់គាត់នៅមន្ទីរស-២១ផង និងថាបើគ្មានការពិនិត្យអំពីការចូលរួមរបស់ឌុច ក្នុងសហកម្មឧក្រិដ្ឋកម្មរួមនេះទេ សាលក្រមមិនអាចនឹងឆ្លុះបញ្ចាំងពីទង្វើព្រហ្មទណ្ឌទាំងមូល និងសារសំខាន់ជាស្នូលនៃតួនាទីរបស់គាត់ នៅក្នុងការប្រព្រឹត្តិទៅ នៅមន្ទីរស-២១បានឡើយ ។ សហកម្មឧក្រិដ្ឋកម្មរួម គឺជាទម្រង់មួយនៃការប្រព្រឹត្តិដោយផ្ទាល់ និងជាទម្រង់ចាំបាច់មួយនៃការទទួលខុសត្រូវ ដើម្បីអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូង សម្រេចបាន

យ៉ាងត្រឹមត្រូវអំពីតួនាទីរបស់ ឌុច ដែលមាននៅក្នុងបទឧក្រិដ្ឋនានាដែលបានប្រព្រឹត្តឡើង នៅមន្ទីរស-២១ ។

### ii. អង្គជំនុំជម្រះសាលាដំបូងមានអំណាចផ្លូវច្បាប់ដើម្បីផ្លាស់ប្តូរការកំណត់បទចោទ

១០. ទោះបីជាវិធាន ៧៧.១៣ ចែងថា សេចក្តីសម្រេចរបស់ អ.ប.ជ ត្រូវបិទផ្លូវតវ៉ា តែនេះមិនមែនតវ៉ាចំពោះសេចក្តីសម្រេចរបស់អ.ប.ជ ទេ ។ ផ្ទុយមកវិញ វិធាន ៩៨ ផ្តល់អំណាចយ៉ាងច្បាស់ដល់អង្គជំនុំជម្រះសាលាដំបូង ដើម្បី "ផ្លាស់ប្តូរការកំណត់បទចោទ" ដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ "ប៉ុន្តែមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ"[10]។ បញ្ញត្តិនេះ អនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូង ស្វែងរកឱ្យឃើញថា សហកម្មឧក្រិដ្ឋកម្មរួម គឺជាទម្រង់មួយនៃការទទួលខុសត្រូវដែលអាចអនុវត្តបាន ។

១១. វិធាន ៩៨.២ ដាក់បញ្ចូលគោលការណ៍នៃច្បាប់ស៊ីវិលដែលគេទទួលស្គាល់ជាទូទៅ គឺគោលការណ៍ *iura novit curia* ("ចៅក្រមយល់ដឹងច្បាប់")[11] ទៅក្នុងនីតិវិធីរបស់អ.វ.ត.ក ។ បើតាមគោល ការណ៍នេះ ចៅក្រមយល់ដឹងច្បាប់ និងមានសេរីភាពអនុវត្តច្បាប់ចំពោះអង្គហេតុនានានៅចំពោះមុខតុលាការ ។ អ្វីដែលបានបញ្ចូលក្នុងអំណាចដែលមានជាប់មកជាមួយរបស់ចៅក្រម គឺសិទ្ធិ មិនជាប់កាតព្វកិច្ច ដើម្បីអនុវត្តនីតិសម្បទាផ្លូវច្បាប់ណាក៏ដោយដែលអាចអនុវត្តបាន ចំពោះ អង្គហេតុនានានៃករណីរឿង ។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាទទួលយកគោលជំហរនេះ[12] ដូចគ្នានឹងតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ដែរ[13] ដែលនេះគឺជា

---

[10] វិធាន ៩៨.២ នៃវិធានផ្ទៃក្នុង ។

[11] *សូមអាន* Kurt Siehr, *សិទ្ធិសញ្ញាទីក្រុងឡាអេ ឆ្នាំ១៩៨០ ស្តីពីទស្សនៈស៊ីវិលអំពីអំពើចាប់ពង្រត់កុមារជាអន្តរជាតិ: បរាជ័យ និងជោគជ័យទៅក្នុងការអនុវត្តន៍របស់ប្រទេសអាល្លឺម៉ង់,* ទិនានុប្បវត្តិ ៣៣ ស្តីពីច្បាប់ និងគោលនយោបាយអន្តរជាតិនៃ មហាវិទ្យាល័យញូយ៉ក (33 New York University Journal of International Law and Policy 207, 211 (2000)) (ដែលរៀបរាប់អំពី iura novit curia (ចៅក្រមស្គាល់ច្បាប់) ថាជា "ភាសិតដ៏ល្បីល្បាញ" មួយនៃនីតិវិធីសម្ងាត់) ។

[12] *សូមអាន* មាត្រា៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ។

តុលាការអន្តរជាតិតែមួយគត់ ដែលទទួលយកធាតុផ្សំសំខាន់ៗនៃនីតិវិធីច្បាប់ស៊ីវិល ។ ដូចបង្ហាញខាងក្រោមត្រង់វាក្យ ខ័ណ្ឌ III ខ, អង្គហេតុនៃសំណុំរឿងលេខ ០០១ គាំទ្រដល់ការរកឃើញនៃសហកម្មឧក្រិដ្ឋកម្មរួម ហើយវិធាន៩៨.២ ផ្តល់សិទ្ធិអំណាចដល់អង្គជំនុំជម្រះសាលាដំបូង ដើម្បីអនុវត្តលើការកំណត់បទចោទឱ្យបានត្រឹមត្រូវចំពោះអង្គហេតុនានា ។

**iii. អង្គជំនុំជម្រះសាលាដំបូងអាចពិចារណាលើការកំណត់អង្គហេតុនានាដែលបានដាក់នៅចំពោះមុខខ្លួន**

១២. នៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន អ.ប.ជ បានទទួលស្គាល់ដោយមិនបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានអំណាចសម្រេចថាតើ ត្រូវអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម ដែរឬអត់ ។ នៅក្នុងកថាខ័ណ្ឌទី១៤១ នៃសាលដីកាលើបណ្តឹងឧទ្ធរណ៍ អ.ប.ជ បានសម្រេចថាខ្លួននឹងមិនបន្ថែមបទចោទសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅក្នុង "ដំណាក់កាល" នៃកិច្ចដំណើរការនេះទេ[14] ។ ការណ៍នេះបង្កប់ន័យថា គេអាចបន្ថែមបាននៅដំណាក់កាលក្រោយមកទៀតនៃកិច្ចដំណើរការនីតិវិធី ។ មេធាវីការពារក្តីយល់ព្រមពីព្រោះគេបានតវ៉ានៅក្នុងសារណាតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាដំណោះស្រាយថា អ.ប.ជ គួរតែច្រានចោលបណ្តឹងឧទ្ធរណ៍ និងផ្ទេរករណីទៅអង្គជំនុំជម្រះសាលាដំបូង ដែលបញ្ហាទាក់ទិននឹងដីកាដំណោះស្រាយ រួមទាំងបញ្ហាសហកម្មឧក្រិដ្ឋកម្មរួម អាចនឹងត្រូវបានដោះស្រាយ[15] ។

១៣. អង្គបុរេជំនុំជម្រះបានគូសបញ្ជាក់ថា អង្គហេតុនានាដែលបានរកឃើញនៅក្នុងអម្លុងពេលនៃកិច្ចស៊ើបសួរ គឺមានលក្ខណៈច្បាស់លាស់ អាចឱ្យយកមកសម្រេចសម្រាប់ការកំណត់បទចោទ "នៅពេលចេញដីកាដំណោះស្រាយ"[16] មិនមែននៅក្នុងដំណាក់កាលផ្សេងនៃកិច្ចដំណើរ

[13] *សូមមើល ឧទាហរណ៍* តុលាការព្រហ្មទណ្ឌអន្តរជាតិ ច្បាប់នានារបស់តុលាការ, ច្បាប់លេខ ៥៥ ("អង្គជំនុំជម្រះ អាចផ្លាស់ប្តូរការកំណត់អង្គហេតុនានាស្របទៅតាមបទឧក្រិដ្ឋ... ឬដើម្បីឱ្យស្របទៅនឹងទម្រង់នៃការចូលរួមរបស់ជនជាប់ចោទ... ដោយមិនធ្វើឱ្យហួសពីអង្គហេតុ និងកាលៈទេសៈនានាដូចបានកំណត់ក្នុងបទចោទ...") ។

[14] កថាខ័ណ្ឌទី១៤១ នៃសាលដីកាលើបណ្តឹងឧទ្ធរណ៍ ។

[15] កថាខ័ណ្ឌទី ៤ នៃចម្លើយរបស់ក្រុមមេធាវីចំពោះបណ្តឹងឧទ្ធរណ៍ ។

[16] កថាខ័ណ្ឌទី៣៩ នៃសាលដីកាលើបណ្តឹងឧទ្ធរណ៍ ។

ការនីតិវិធីទេ។ អនុលោមតាមវិធាន៧៩.១ ដីកាបញ្ជូនរឿងទៅជំនុំជម្រះនឹងបំរើជា“មូលដ្ឋាន” សម្រាប់ការកាត់សេចក្តី[17] ប៉ុន្តែ បើតាមការគូសបញ្ជាក់យ៉ាងច្បាស់នៃវិធាន៩៨.២ ការកំណត់បទចោទរបស់វិធាននេះ មិនចងកាតព្វកិច្ចចំពោះអង្គជំនុំជម្រះសាលាដំបូងទេ ដោយសារតែអង្គជំនុំជម្រះសាលាដំបូងមានអំណាចដើម្បីសម្រេចលើបញ្ហានេះ នៅក្នុងអម្លុងពេលនៃសវនាការ បន្ទាប់ពីមានការយល់ពីតម្លៃនៃភស្តុតាងដែលបាននាំមកចំពោះមុខខ្លួន។

១៤. អំណាចរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីពិនិត្យឡើងវិញលើបញ្ហានានាដែលបានលើកពីដំបូង ដោយ អ.ប.ជ ត្រូវបានទទួលស្គាល់នៅក្នុង “សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្កេកអ៊ាវ ហៅ “ឌុច”[18] និងជាថ្មីម្តងទៀតនៅក្នុង“សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ អៀង សារី”[19] ។ អ.ប.ជ បានសម្រេចថា៖

> អង្គបុរេជំនុំជម្រះ មិនមានហេតុផលសមស្របក្នុងការធ្វើសេចក្តីសម្រេច ចំពោះហេតុការណ៍នីមួយៗ នៅពេលដែលស្ថាប័នតុលាការមួយផ្សេងទៀត អាចចាប់យករឿងក្តីនេះទៅជំនុំជម្រះនិងចេញសេចក្តីសម្រេចដោយផ្ទាល់ខ្លួន ដោយផ្អែកលើភស្តុតាង និងការដាក់សេចក្តីសន្និដ្ឋាន ផ្សេងៗ”[20] នៅចំពោះមុខខ្លួនឡើយ ។

១៥. ស្រដៀងគ្នានេះដែរ នៅក្នុង “សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ អៀង សារី” អ.ប.ជ បានប្រកាសជាថ្មីម្តងទៀតថា ខ្លួនគ្មានអំណាចធ្វើការសម្រេចសន្និដ្ឋានចំពោះបញ្ហាផ្នែកច្បាប់នានា ដែលនឹងត្រូវលើកឡើងចំពោះមុខ អង្គជំនុំជម្រះ

---

[17] *ដូចមុនដដែល,* កថាខ័ណ្ឌទី៤០ ។

[18] កថាខ័ណ្ឌទី៦៣ នៃសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្កេកអ៊ាវ ហៅ “ឌុច”, ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៧, C5/45 ។

[19] កថាខ័ណ្ឌទី៥៣ នៃសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ អៀង សារី, ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨, C22/I/73 ។

[20] កថាខ័ណ្ឌទី៦៣ នៃសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្កេកអ៊ាវ ហៅ “ឌុច”, ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៧, C5/45 ។

សាលាដំបូងទេ ។ អ.ប.ជ បានសន្និដ្ឋានថា គេមិនអាចសម្រេចថាតើ ការជំនុំជម្រះក្នុងឆ្នាំ ១៩៧៩ របស់ អៀង សារី និងការកាត់ឱ្យជាប់ចោទដោយតុលាការប្រជាជនបដិវត្តន៍ នឹងអាចរារាំងដល់ការកាត់ទោសម្តងទៀតដោយ អ.វ.ត.ក ឡើយ[21] ។ ហេតុដូចនេះ អ.ប.ជ បានទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូង មានសិទ្ធិអំណាចពិនិត្យឡើងវិញលើបញ្ហានានា ដូចដែលបានលើកឡើងនៅចំពោះមុខ អ.ប.ជ ប្រសិនបើ ដំណោះស្រាយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងមានភាពសមស្របជាង ។ ដូចដែលការអនុវត្តន៍សហកម្មឧក្រិដ្ឋកម្មរួមធ្លាក់ទៅលើអង្គហេតុនានា ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅក្នុងអម្លុងពេលសវនាការជំនុំជម្រះ និងនីតិសម្បទាខាងផ្លូវច្បាប់នៃអង្គហេតុទាំងនោះ សេចក្តីសម្រេចថាតើ សហកម្មឧក្រិដ្ឋកម្មរួម ត្រូវអនុវត្តឬអត់ គឺនឹងត្រូវបានដោះស្រាយយ៉ាងសមស្របបំផុតដោយអង្គជំនុំជម្រះសាលាដំបូង ។

១៦. សេចក្តីសម្រេចទាំងនេះរបស់អ.ប.ជឆ្លុះបញ្ចាំងឱ្យឃើញនូវការសម្រេចស្រដៀងគ្នាដទៃទៀតដែលមាននៅតាមបណ្តាតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត ដូចជា តុលាការព្រហ្មទណ្ឌអន្តរជាតិជាដើម ។ ស្រដៀងគ្នានឹង អ.វ.ត.ក ដែរ តុលាការ ICC ក៏មាន អ.ប.ជ មួយដែរសម្រាប់កិច្ចដំណើរការនីតិវិធីមុនអង្គសេចក្តី ។ មាត្រា ១៩.៦ នៃច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមចែងយ៉ាងច្បាស់លាស់ថា នៅពេលធ្វើការបញ្ជាក់អះអាងអំពីបទចោទ ការប្រឈមមុខនៅក្នុងការទទួលយកករណីណាមួយ "ត្រូវតែបានបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង" ដោយផ្តល់ការអនុញ្ញាតដល់អង្គជំនុំជម្រះសាលាដំបូង ដើម្បីដកចេញ ឬកែប្រែបទចោទ ឬផ្លាស់ប្តូរការទទួលយកករណីនោះ[22] ។ តាមបញ្ញត្តិនៃច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម អង្គជំនុំជម្រះសាលាដំបូងអាច "ប្រើប្រាស់មុខងាររបស់អង្គបុរេជំនុំជម្រះណាមួយក៏បាន ដូចដែលបានយោង នៅក្នុងកថាខណ្ឌទី១១ នៃមាត្រា ៦១"[23] ។ ជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូង អាចកែប្រែ ឬដកចេញបទចោទប្រកាន់បាន ។

[21] កថាខណ្ឌទី៥៣ នៃសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ អៀង សារី, ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨, C22/I/73 ។

[22] *សូមអាន* មាត្រា១៩.៦ នៃច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម ។

[23] *ដូចមុនដដែល*, មាត្រា៦៤.៦.ក ។

១៧. នៅក្នុងករណី *Lubanga,* អ.ប.ជ បានអះអាងអំពីសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីផ្លាស់ប្តូរការកំណត់អង្គហេតុ ដូចបានកំណត់នៅក្នុង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ នៅក្នុងសេចក្តីសម្រេចចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៧[24] អ.ប.ជនៃតុលាការICC បានបដិសេធលើពាក្យសុំទាំងរបស់រដ្ឋអាជ្ញា និងរបស់មេធាវីការពារក្តី ដែលសុំប្តឹងតវ៉ាលើការអះអាងអំពីបទចោទរបស់ អ.ប.ជ ។ នៅក្នុងការបដិសេធពាក្យសុំប្តឹងរបស់ភាគីនេះ អ.ប.ជ បានធ្វើការកត់សំគាល់ថា គ្មានអ្វីដែលត្រូវ "រារាំងសហព្រះរាជអាជ្ញា ឬមេធាវីការពារក្តី ដល់ការស្នើសុំទៅអង្គជំនុំជម្រះសាលាដំបូង មិនឱ្យពិចារណាទៅលើការកំណត់ អំពីអង្គហេតុដែលបានកំណត់នៅក្នុងបទចោទប្រឆាំងនឹង Thomas Lubanga Dyilo និងដូចដែលបានកំណត់ដោយ [អង្គបុរេ] ជំនុំជម្រះបានទេ"[25] ។

១៨. ដោយសារ អ.ប.ជ បានទទួលស្គាល់យ៉ាងជាប់លាប់មកហើយ ដែលថាពីដំបូងឡើយ បញ្ហាទាំងនេះត្រូវបានយកមកនៅចំពោះមុខខ្លួន ដែលអាចនឹងត្រូវបានធ្វើសវនាការឡើងវិញ និងត្រូវបានធ្វើការវិនិច្ឆ័យដោយអង្គជំនុំជម្រះផ្សេងៗទៀត ដែលអង្គជំនុំជម្រះសាលាដំបូង មិនមានជាប់កាតព្វកិច្ចតាមសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងសហកម្មឧក្រិដ្ឋកម្មរួមទេ ។ វិធាន ៩៨.២ នៃវិធានផ្ទៃក្នុងបានផ្តល់ដល់អង្គជំនុំជម្រះសាលាដំបូង នូវសិទ្ធិអំណាចដែលមានជាប់មកជាមួយ ក្នុងការផ្លាស់ប្តូរបទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយ អ.ប.ជ មិនអាចកំណត់សមត្ថកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការផ្លាស់ប្តូរបទចោទបានទេ សូម្បីតែការផ្លាស់ប្តូរបទចោទនោះជាចេតនាពីមុនរបស់ អ.ប.ជ ក៏ដោយ ។

**iv. អង្គជំនុំជម្រះសាលាដំបូងមានអំណាចផ្លូវច្បាប់ដើម្បីបើកកិច្ចស៊ើបសួរដោយខ្លួនឯង**

---

[24] *រដ្ឋអាជ្ញា ទល់នឹង Lubanga Dyilo*, សេចក្តីសម្រេចលើពាក្យសុំទាំងរបស់រដ្ឋអាជ្ញា និងមេធាវីការពារក្តី ដែលសុំប្តឹងឧទ្ធរណ៍លើការបញ្ជាក់អះអាងអំពីបទចោទ, សំណុំរឿងលេខ: ICC-01/04-01/06, អង្គបុរេជំនុំជម្រះ I, ចុះថ្ងៃទី១៤ ឧសភា ២០០៧), *អាចរកបានតាមរយៈ:* http://www.icc-cpi.int/library/cases/ICC-01-04-01-06-915_ English.pdf ("សេចក្តីសម្រេចក្នុងករណី Lubanga") ។

[25] សេចក្តីសម្រេចក្នុងករណី Lubanga, កថាខ័ណ្ឌទី ៤៤ ។

១៩. វិធាន ៩៣ នៃវិធានផ្ទៃក្នុងបានអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូង អាចធ្វើការស៊ើបសួរបន្ថែមដោយខ្លួនឯងបាន និងបានបង្ហាញផងដែរថាអង្គជំនុំជម្រះសាលាដំបូង មិនអាចជាប់កាតព្វកិច្ចតាមសេចក្ដីសម្រេចទាំងឡាយរបស់ អ.ប.ជ ស្ដីពីការផ្លាស់ប្ដូរបទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបានទេ ។ វិធាន ៩៣ នៃវិធានផ្ទៃក្នុងបានផ្ដល់ដល់អង្គជំនុំជម្រះសាលាដំបូងនូវសិទ្ធិក្នុងការធ្វើការស៊ើបសួរថ្មីៗ "ដែលត្រូវស្ថិតនៅក្រោមល័ក្ខខ័ណ្ឌដូចគ្នាទៅនឹងសហចៅក្រមស៊ើបអង្កេតដែរ" ។ វាមិនសមហេតុសមផលចំពោះអង្គជំនុំជម្រះសាលាដំបូងទេ បើគ្រាន់តែមានសិទ្ធិអំណាចនេះ ក៏ប៉ុន្តែមិនមានសិទ្ធិអំណាចក្នុងការផ្លាស់ប្ដូរបទចោទ ដើម្បីឱ្យមានលក្ខណៈសមស្រប ទៅនឹងលទ្ធផលនៃការស៊ើបសួររបស់ខ្លួនទៅតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង ។ វិធាន ៩៨.២ និង ៩៣ នៃវិធានផ្ទៃក្នុង ទាំងពីរនេះបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានសិទ្ធិអំណាចក្នុងការផ្លាស់ប្ដូរបទចោទ ដែលបានកំណត់នៅក្នុង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលសិទ្ធិអំណាចនេះមិនអាចត្រូវបានកំរិតដោយសេចក្ដីសម្រេច របស់ អ.ប.ជ ឡើយ ។

២០. អង្គជំនុំជម្រះសាលាដំបូង គួរតែអនុវត្តនូវអំណាចរបស់ខ្លួន ទៅតាមវិធាន ៩៨.២ នៃវិធានផ្ទៃក្នុងនៅក្នុងការពិនិត្យមើលសំណុំរឿង ការដឹកនាំធ្វើសវនាការ និងធ្វើការកំណត់បទចោទឱ្យបានត្រឹមត្រូវដោយយោងលើអង្គហេតុជាមូលដ្ឋាន។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គហេតុទាំងនោះបង្ហាញអំពីការចូលរួមរបស់ ឌុច នៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម ។

## ខ. សហព្រះរាជអាជ្ញា បានជជែកការពារយ៉ាងត្រឹមត្រូវអំពី សហកម្មឧក្រិដ្ឋកម្មរួម ហើយ ឌុច ទទួលបាននូវការជូនដំណឹងយ៉ាងគ្រប់គ្រាន់

### i. សហកម្មឧក្រិដ្ឋកម្មរួម ត្រូវបានជជែកការពារយ៉ាងត្រឹមត្រូវ

២១. អ.ប.ជ បានជ្រើសរើសយកការមិនដាក់បញ្ចូលនូវសហកម្មឧក្រិដ្ឋកម្មរួម ទៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ឌុច ពីព្រោះ អ.ប.ជ មិនត្រូវបានផ្ដល់នូវព័ត៌មានឱ្យបានគ្រប់គ្រាន់អំពី

ការចូលរួមរបស់គាត់នៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម[26] និងពីព្រោះ សហព្រះរាជអាជ្ញា ត្រូវបានចោទថា មិនបានធ្វើការជជែកការពារអំពីវត្តមាននៃសហកម្មឧក្រិដ្ឋកម្មរួមមួយ ដែលមានវិសេសភាពគ្រប់គ្រាន់នោះទេ[27] ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អ.ប.ជ មានការភាន់ច្រឡំនៅក្នុងការរកឃើញនូវធាតុផ្សំនៃសហកម្មឧក្រិដ្ឋកម្មរួម មិនបានជជែកការពារឱ្យបានត្រឹមត្រូវ និងមានការភាន់ច្រឡំនៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនថា ឌុច មិនបានទទួលនូវការជូនដំណឹងឱ្យបានគ្រប់គ្រាន់ទេ ។

២២. ចង់និយាយពីដំបូងថា សហព្រះរាជអាជ្ញា បានជជែកការពារយ៉ាងត្រឹមត្រូវអំពីសហកម្មឧក្រិដ្ឋកម្មរួម ។ ដោយយោងទៅតាមករណីយុត្តិសាស្ត្រអន្តរជាតិ រដ្ឋអាជ្ញាគ្រាន់តែត្រូវបានតម្រូវឱ្យធ្វើការពន្យល់អំពីអង្គហេតុទាំងឡាយ ដើម្បីជជែកការពារអំពីសហកម្មឧក្រិដ្ឋកម្មរួមឱ្យបានត្រឹមត្រូវដូចតទៅនេះ៖ ទី១) ចរិកលក្ខណៈ និងគោលបំណងនៃសហកម្មឧក្រិដ្ឋកម្មរួម ទី២) ពេលវេលា ឬរយៈពេលដែលសហកម្មនោះត្រូវបានគេនិយាយថាមានអត្ថិភាព និងទី៣) អត្តសញ្ញាណរបស់ពួកដែលបានចូលរួមចំណែក នៅក្នុងសហកម្មនោះ[28] ។ អ.ប.ជ សំអាងដោយមានការយល់ច្រឡំទៅលើករណីរបស់ *Kvočka* ដើម្បីគាំទ្រសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលថា សហព្រះរាជអាជ្ញា មិនបានជជែកការពារឱ្យបានត្រឹមត្រូវ អំពីបញ្ហាសហកម្មឧក្រិដ្ឋកម្មរួម[29] ។ ទោះជាយ៉ាងដូច្នេះក៏ដោយក៏ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ បានសម្រេចនៅក្នុងករណីរបស់ *Kvočka* ថារដ្ឋអាជ្ញាគ្រាន់តែត្រូវបានតម្រូវឱ្យ៖ ទី១) "ធ្វើការជជែកការពារ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នូវគ្រប់អង្គហេតុសំខាន់ៗទាំងអស់ ដែលចង្អុលជាភស្តុតាង

---

[26] សាលដីកាលើបណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី ១៣៨, ១៤១ ។

[27] *ដូចមុនដដែល*, កថាខណ្ឌទី ១៣៥ ។

[28] *រដ្ឋអាជ្ញា ទល់នឹង Niyitegeka,* សាលដីកាលើបណ្តឹងឧទ្ធរណ៍, សំណុំរឿងលេខ: ICTR-96-14-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ថ្ងៃទី០៩ កក្កដា ២០០៤, កថាខណ្ឌទី ១៩៣ ។ *រដ្ឋអាជ្ញា ទល់នឹង Martic,* សេចក្តីសម្រេចលើញត្តិបឋមជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើវិសោធនកម្ម, សំណុំរឿងលេខ IT-95-11-PT, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី០២ មិថុនា ២០០៣, កថាខណ្ឌទី ១២ ។ *រដ្ឋអាជ្ញា ទល់នឹង Galic,* សេចក្តីសម្រេចលើពាក្យសុំប្តឹងឧទ្ធរណ៍ដែលដាក់ដោយមេធាវីការពារក្តី, សំណុំ រឿងលេខ IT-98-29-AR72, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ថ្ងៃទី៣០ វិច្ឆិកា ២០០១, កថាខណ្ឌទី ១៥ ។ *រដ្ឋអាជ្ញា ទល់នឹង Kupreskic និងគូកន,* សាលដីកាលើបណ្តឹងឧទ្ធរណ៍, សំណុំរឿងលេខ IT-95-16-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ថ្ងៃទី២៣ តុលា ២០០១, កថាខណ្ឌទី ៨៩ ។

[29] សាលដីកាលើបណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី ១៣៥, កំណត់សម្គាល់លេខ ៩០ ។

គាំទ្រដល់ការចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក៏ប៉ុន្តែមិនមែនជាភស្តុតាងដែលជាសក្ខីកម្ម សម្រាប់បង្ហាញនូវអង្គហេតុសំខាន់ៗនោះទេ"[30] ដោយរួមទាំង "គោលបំណងនៃសហកម្ម, អត្តសញ្ញាណរបស់អ្នកចូលរួមចំណែក និងចរិកលក្ខណៈនៃការចូលរួមចំណែករបស់ជនជាប់ចោទនៅក្នុងសហកម្មផង"[31] និងទី២) "ធ្វើការចង្អុលបញ្ជាក់ឲ្យបានច្បាស់លាស់ថាតើទម្រង់ [សហកម្មឧក្រិដ្ឋកម្មរួម] ណាមួយ ដែលកំពុងត្រូវបានធ្វើការចោទប្រកាន់"[32] ។

២៣. នៅក្នុងករណីរបស់ *Kvočka* តុលាការពិតជាបានលើកឡើងថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមួយអាចនឹងត្រូវបានចាត់ទុកថានៅមានខ្វះ បើអង្គហេតុសំខាន់ៗ មិនត្រូវបានជជែកការពារប្រកបទៅដោយ "វិសេសភាពគ្រប់គ្រាន់"[33] ។ ទោះជាយ៉ាងដូច្នេះក៏ដោយក៏ ឧទាហរណ៍អំពីវិសេសភាពមិនគ្រប់គ្រាន់ដែលត្រូវបានផ្តល់ឲ្យដោយអង្គជំនុំជម្រះនោះ - "នៅពេលដែលពេលវេលាយោងទៅដល់លំដាប់កាលបរិច្ឆេទទូលំទូលាយ ទីកន្លែងគ្រាន់តែត្រូវបានចង្អុលបញ្ជាក់ជាទូទៅប៉ុណ្ណោះ និងជនរងគ្រោះគ្រាន់តែត្រូវបានកំណត់អត្តសញ្ញាណជាទូទៅប៉ុណ្ណោះ"[34] - បានបង្ហាញថា ព័ត៌មានដែលផ្តល់ជូនដោយសហព្រះរាជអាជ្ញា នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[35] និងនៅក្នុងដីកាសន្និដ្ឋានស្ថាពរ[36] គឺមានលក្ខណៈយ៉ាងជាក់លាក់គ្រប់គ្រាន់ដើម្បីឲ្យត្រូវទៅតាមលក្ខខណ្ឌតម្រូវក្នុងការជជែកការពារអំពីបញ្ហាសហកម្មឧក្រិដ្ឋកម្មរួមបានហើយ។

២៤. ដោយឡែក សហព្រះរាជអាជ្ញា បានជជែកការពារនូវគ្រប់ធាតុផ្សំចាំបាច់ទាំងអស់ ដើម្បីគាំទ្រដល់សហកម្មឧក្រិដ្ឋកម្មរួមមួយនៅក្នុងដីកាសន្និដ្ឋានស្ថាពរ ។ សហព្រះរាជអាជ្ញា បានធ្វើការ

---

[30] *រដ្ឋអាជ្ញា ទល់នឹង Kvočka និងគូកន,* សាលដីកា, សំណុំរឿងលេខ IT-98-30/1-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ថ្ងៃទី២៨ កុម្ភៈ ២០០៥, កថាខណ្ឌទី ២៧ ។

[31] *ដូចមុនដដែល, កថាខណ្ឌទី ២៨, ៤២ ។*

[32] *ដូចមុនដដែល, កថាខណ្ឌទី ២៨ ។*

[33] *ដូចមុនដដែល, កថាខណ្ឌទី ៣០ ។*

[34] *ដូចមុនដដែល ។*

[35] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ, ចុះថ្ងៃទី១៨ កក្កដា ២០០៧, កថាខណ្ឌទី ៥-១៦ និង ៣៧-៧២ ។

[36] ដីកាសន្និដ្ឋានស្ថាពរ, កថាខណ្ឌទី ២៥០-២៥៣ ។

កំណត់យ៉ាងច្បាស់លាស់អំពីរយៈពេលនៃសហកម្មឧក្រិដ្ឋកម្មរួម ព្រមទាំងចរិកលក្ខណៈ និង គោលបំណងនៃសហកម្មឧក្រិដ្ឋកម្មរួមនោះ នៅក្នុងកថាខណ្ឌទី ២៥០ នៃដីកាសន្និដ្ឋានស្ថាពរ៖

*ភស្តុតាងក្នុងសំណុំរឿង និងឯកសារយោងក្នុងអង្គហេតុជាក់ស្តែងនៃដីកាសន្និដ្ឋានស្ថាពរនេះ បង្ហាញថា **ឌុច** បានប្រព្រឹត្តអំពើឧក្រិដ្ឋជាច្រើនក្នុងឋានៈគាត់ជាអ្នកចូលរួមម្នាក់នៅក្នុង សហកម្មឧក្រិដ្ឋកម្មរួម ។ សហកម្មឧក្រិដ្ឋកម្មរួម ចាប់ផ្តើមមានអត្ថិភាពចាប់តាំងពីថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ មក គឺនៅពេលដែល **សុន សេន** បានណែនាំទៅ **ណាត** និង **ឌុច** ឲ្យ រៀបចំបង្កើតជាមន្ទីរស-២១ ។ សហកម្មឧក្រិដ្ឋកម្មរួមបានមានអត្ថិភាពចាប់តាំងពីមន្ទីរស-២១ បានដំណើរការទាំងស្រុងនៅក្នុងខែតុលា ឆ្នាំ១៩៧៥ រហូតដល់ ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ពេលដែលរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ។ គោលបំណងនៃសហកម្មឧក្រិដ្ឋកម្មរួម គឺការចាប់ខ្លួន ការឃុំឃាំង ប្រព្រឹត្តិកម្មឃោរឃៅ ការសួរចម្លើយ ការធ្វើទារុណកម្ម និងការកំទេចចោលជាលក្ខណៈប្រព័ន្ធចំពោះ "ខ្មាំង" ទាំងអស់របស់របបកម្ពុជាប្រជាធិបតេយ្យ ដោយការប្រព្រឹត្តនូវអំពើឧក្រិដ្ឋផ្សេងៗ ដូចដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានស្ថាពរនេះស្រាប់ ។ គឺជាប្រព័ន្ធសម្រាប់ធ្វើការគាបសង្កត់ដែលមានការរៀបចំមួយ ដែលមានអត្ថិភាពនៅមន្ទីរស-២១ ចាប់តាំងពីពេលកកើតនៃសហកម្មឧក្រិដ្ឋកម្មរួម រហូតដល់ចុងបញ្ចប់របស់វា ។ រាល់ឧក្រិដ្ឋកម្មទាំងអស់ដែលបានកើតឡើងនៅមន្ទីរស-២១ ដូចដែលបានរៀបរាប់ក្នុងដីកាសន្និដ្ឋានស្ថាពរនេះ គឺសុទ្ធតែស្ថិតនៅក្នុងគោលបំណងនៃសហកម្មឧក្រិដ្ឋរួមនេះ[37] ។*

២៥. នៅក្នុងកថាខណ្ឌទី ២៥១ នៃដីកាសន្និដ្ឋានស្ថាពរ សហព្រះរាជអាជ្ញា បានធ្វើការកំណត់អត្តសញ្ញាណនៃអ្នកចូលរួមចំណែកនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម៖

*ឌុច បានចូលរួមប្រព្រឹត្តនៅក្នុងទូទាំងអំឡុងពេលដែលសហកម្មឧក្រិដ្ឋរួមនេះ មានអត្ថិភាពរួមគ្នាជាមួយនិងអ្នកចូលរួមដទៃៗទៀត នៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមនេះ ដែលពួកគេទាំងនោះបានចូលរួមនៅក្នុងរយៈពេលខុសៗពីគ្នាដោយរាប់ទាំងអតីតប្រធានមន្ទីរស-២១ ឈ្មោះ*

---

[37] *ដូចមុនដដែល,* កថាខណ្ឌទី ២៥០ ។

*ណាត និងសមាជិកដទៃៗទៀតនៃគណៈកម្មាធិការមន្ទីរស-២១ ពោលគឺ **ឃឹម វ៉ាត ហៅ ហ៊ី** និង **ហ៊ុយ ស្រែ** ព្រមទាំងអ្នកនៅក្រោមបង្គាប់របស់ពួកគេផងដែរ*[38] ។

២៦. នៅក្នុងកថាខណ្ឌទី ២៥២ និង ២៥៣ នៃដីកាសន្និដ្ឋានស្ថាពរ សហព្រះរាជអាជ្ញា បានធ្វើការកំណត់យ៉ាងច្បាស់លាស់អំពីទម្រង់ជាក់លាក់នានានៃសហកម្មឧក្រិដ្ឋកម្មរួមដែល ឌុច បានចូលរួមចំណែក៖

> *ឌុច បានចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួមក្នុងនាមជា សហចារីមួយរូប ។ ឌុច និងសមាជិកផ្សេងៗទៀតនៃសហកម្មឧក្រិដ្ឋកម្មរួម បានប្រព្រឹត្តដោយអនុលោមទៅតាមគោលបំណងរួមនេះ និងដោយមានចេតនារួមគ្នាមួយ ដើម្បីធ្វើឲ្យកើតមានទូវគោលបំណងរួមនេះ **(ទម្រង់ "ជាមូលដ្ឋាន"នៃសហកម្មឧក្រិដ្ឋកម្មរួម)** ។ លើសពីនេះទៀត ឌុច បានចូលរួមយ៉ាងសកម្មក្នុងការពង្រឹងអនុវត្តនូវប្រព័ន្ធសម្រាប់ធ្វើការគាបសង្កត់នៅក្នុងមន្ទីរស-២១ ក្នុងឋានៈគាត់ជាអនុប្រធាន និងក្រោយមកជាប្រធាន។ ឌុច បានដឹងយ៉ាងច្បាស់អំពីស្ថានភាពនៃប្រព័ន្ធសម្រាប់ធ្វើការគាបសង្កត់នៅមន្ទីរស-២១ នេះ។ ដោយរួមសហការគ្នាជាមួយសមាជិកផ្សេងៗទៀតនៃសហកម្មឧក្រិដ្ឋកម្មរួម ឌុច មានចេតនាពង្រីកប្រព័ន្ធសម្រាប់ធ្វើការគាបសង្កត់បន្ថែមទៀតនៅមន្ទីរស-២១ **(ទម្រង់ជា "ប្រព័ន្ធ" នៃសហកម្មឧក្រិដ្ឋកម្មរួម)***[39] ។
>
> *ម៉្យាងទៀត ឧក្រិដ្ឋកម្មទាំងឡាយដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានស្ថាពរនេះ គឺជាផលវិបាកជាធម្មជាតិ និងអាចរំពឹងទុកជាមុនបាន នៃការអនុវត្តន៍គោលបំណងនៃសហកម្មឧក្រិដ្ឋកម្មរួម ។ ឌុច បានដឹងថា ឧក្រិដ្ឋកម្មទាំងនេះ គឺជាផលវិបាកដែលអាចនឹងកើតឡើងពីសហកម្មឧក្រិដ្ឋកម្មរួមរបស់មន្ទីរស-២១ និងដោយសារតែការដឹងបែបនេះហើយបានជា ឌុច សម្រេចចិត្តចូលរួមក្នុងសហកម្មឧក្រិដ្ឋរួមនេះ**(ទម្រង់"ដែលត្រូវបានពង្រីកបន្ថែម" នៃសហកម្មឧក្រិដ្ឋរួម)** ។ ឌុច អាចទាយទុកជាមុនថាចារីពីខាងក្រៅដែលមានសក្តានុពលអាចនឹងប្រព្រឹត្តនូវឧក្រិដ្ឋកម្មឃោរឃៅនៅក្នុងពេលបំពេញភារកិច្ចរបស់ពួកគេ ដែលទោះបីជាបានដឹងបែបនេះហើយក្តី ក៏គាត់នៅតែចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួមនេះទៀត*[40] ។

---

[38] *ដូចមុនដដែល*, កថាខណ្ឌទី ២៥១ ។

[39] *ដូចមុនដដែល*, កថាខណ្ឌទី ២៥២ (សង្កត់ន័យបន្ថែមត្រង់**អក្សរដិតធំ**) ។

[40] *ដូចមុនដដែល*, កថាខណ្ឌទី ២៥៣ (សង្កត់ន័យបន្ថែមត្រង់**អក្សរដិតធំ**) ។

២៧. ចរិកលក្ខណៈនៃអ្នកចូលរួមចំណែករបស់ ឌុច នៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម ត្រូវបានសង្ខេប នៅក្នុងកថាខណ្ឌទី ២៥០-២៥៣ នៃដីកាសន្និដ្ឋានស្ថាពរ ហើយក៏ត្រូវបានធ្វើការពន្យល់យ៉ាង ពិស្តារផងដែរនៅក្នុងកថាខណ្ឌទី ១៣៨-១៦៣ នៃដីកាសន្និដ្ឋានស្ថាពរ ។ វគ្គអត្ថបទទាំងនោះ បានបង្ហាញយ៉ាងច្បាស់លាស់ថា លក្ខខណ្ឌតម្រូវនានាដែលចាំបាច់សម្រាប់ជដែកការពារឲ្យ បានត្រឹមត្រូវអំពីបញ្ហាសហកម្មឧក្រិដ្ឋកម្មរួមនោះ សហព្រះរាជអាជ្ញា ធ្លាប់បានធ្វើយ៉ាងត្រឹម ត្រូវទៅតាមនោះរួចរាល់អស់ហើយថា អ.ប.ជ បានភាន់ច្រឡំនៅក្នុងការសន្និដ្ឋានថា សហ ព្រះរាជអាជ្ញា មិនធ្លាប់ដែលបានជដែកការពារឲ្យបានត្រឹមត្រូវអំពីបញ្ហាសហកម្មឧក្រិដ្ឋកម្មរួម នោះទេ ។

### ii. ការជូនដំណឹង

២៨. អ.ប.ជ បានកត់សម្គាល់ឃើញថា ជនចាប់ចោទ "មានសិទ្ធិទទួលបានការជូនដំណឹងអំពីបទ ចោទនៅក្នុងដំណាក់កាលស៊ើបសួរ ត្រឹមកម្រិតមួយដែលអាចឲ្យគាត់អនុវត្តសិទ្ធិដែលផ្តល់ជូន គាត់នៅក្នុងអំឡុងពេលនៃការស៊ើបសួរ"[41] ។ នៅពេលដែលសហព្រះរាជអាជ្ញា មិនជំទាស់នឹង សេចក្តីថ្លែងអំពីអង្គច្បាប់នេះ ជនជាប់ចោទត្រូវបានទទួលនូវព័ត៌មានអំពីបទចោទយ៉ាងគ្រប់ គ្រាន់រួចទៅហើយ ដូចដែលបានបង្ហាញដោយអង្គហេតុផ្សេងៗ មានដាក់ជាគោលៗនៅក្នុង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយសេចក្តីបន្ថែមនៃទម្រង់នៃការទទួលខុសត្រូវ ដែលមាន មូលដ្ឋាននៅលើអង្គហេតុទាំងនោះ មិនមានការខូចខាតប្រយោជន៍/ការបាត់បង់សិទ្ធិ ខាងផ្នែក ការពារក្តីនោះទេ ។

២៩. គោលបំណងនៃការជូនដំណឹងអំពីបទចោទដល់ជនត្រូវចោទ ឬជនជាប់ចោទគឺដើម្បីជៀសវាង នូវការខូចខាតប្រយោជន៍/ការបាត់បង់សិទ្ធិរបស់ជនជាប់ចោទ នៅក្នុងការត្រៀមរៀបចំ និង

[41] សាលដីកាលើបណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី ១៣៨ ។

ចាត់ដំណើរការការពារក្ដីរបស់ខ្លួន[42] ។ ការខូចខាតប្រយោជន៍/ការបាត់បង់សិទ្ធិមិនបានកើតឡើងទេ នៅពេលដែលមានការចោទប្រកាន់បន្ថែម ឬទម្រង់នៃការទទួលខុសត្រូវថ្មីត្រូវបានដាក់បន្ថែមនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមានមូលដ្ឋាននៅលើអង្គហេតុនានាដែលត្រូវបានដាក់បញ្ចូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដើម[43] ។ នៅក្នុងករណីនេះ ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានផ្ទុកនូវគ្រប់អង្គហេតុ ទាំងអស់ដែលចាំបាច់សម្រាប់ធ្វើការបញ្ជូន **ឌុច** ទៅជំនុំជម្រះអំពីការចូលរួមរបស់គាត់ នៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម ។ ក្រុមនៃបុគ្គលដែលបានចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម ត្រូវបានពិពណ៌នានៅក្នុងកថាខណ្ឌទី ២០, ២១ និង ២២ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងមានរួមទាំងសមាជិកនានានៃគណៈកម្មាធិការមន្ទីរស-២១ ផង ។ ដូចដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះបានរៀបរាប់រួចមកហើយថា[44] បំណងប្រាថ្នាដែលមិនបានតវ៉ារបស់មន្ទីរស-២១ នោះគឺការកំណត់អត្តសញ្ញាណរបស់ "ខ្មាំង" ពិតប្រាកដឬដែលបានចោទប្រកាន់ទោស និងមានការចាប់ខ្លួនដោយខុសច្បាប់ ការឃុំឃាំង ការធ្វើទារុណ កម្ម និងការសម្លាប់ ជាបន្តបន្ទាប់ ។ គោលបំណងរួមនៃគណៈកម្មាធិការមន្ទីរស-២១ ដោយរាប់ទាំង ឌុច ផង គឺដើម្បីធ្វើឱ្យបានសម្រេចនូវបំណងប្រាថ្នាផ្សេងៗដោយការប្រព្រឹត្តិនូវឧក្រិដ្ឋកម្មនានា ដែលបានពិពណ៌នានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ ដីកាបញ្ជូនរឿងទៅ

---

[42] *រដ្ឋអាជ្ញា ទល់នឹង Martic,* សេចក្ដីសម្រេចលើសេចក្ដីសន្និដ្ឋានរបស់រដ្ឋអាជ្ញា ស្នើសុំដាក់សេចក្ដីកែតម្រូវលើដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើវិសោធនកម្ម, សំណុំរឿងលេខ IT-95-11-PT, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី១៣ ធ្នូ ២០០២, កថាខណ្ឌ២៣ ។ *រដ្ឋអាជ្ញា ទល់នឹង Naletilic និង Martinovic,* សេចក្ដីសម្រេចលើការជំទាស់របស់ Vinko Martinovic ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើវិសោធនកម្ម និងសេចក្ដីសម្រេចលើញត្តិបឋមរបស់ Mladen Naletilic ជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើវិសោធនកម្ម, សំណុំរឿងលេខ IT-98-34-PT, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី១៤ កុម្ភៈ ២០០១, ទំព័រទី ៦។

[43] *រដ្ឋអាជ្ញា ទល់នឹង Naletilic និង Martinovic,* សេចក្ដីសម្រេចលើការជំទាស់របស់ Vinko Martinovic ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើវិសោធនកម្ម និងសេចក្ដីសម្រេចលើញត្តិបឋមរបស់ Mladen Naletilic ជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើវិសោធនកម្ម, សំណុំរឿងលេខ IT-98-34-PT, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី១៤ កុម្ភៈ ២០០១, ទំព័រទី ៤-៧។ *រដ្ឋអាជ្ញា ទល់នឹង Halilovic,* សេចក្ដីសម្រេចលើសេចក្ដីសន្និដ្ឋានរបស់រដ្ឋអាជ្ញាស្នើសុំធ្វើវិសោធនកម្មលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ, សំណុំរឿងលេខ IT-01-58-PT, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី១៧ ធ្នូ ២០០៤, កថាខណ្ឌទី ២២ ។ *រដ្ឋអាជ្ញា ទល់នឹង Mejakic និងគូកន,* សេចក្ដីសម្រេចលើដីកាបញ្ជូនរឿងទៅជំនុំជម្រះសរុប, សំណុំរឿងលេខ IT-02-65-PT, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី២១ វិច្ឆិកា ២០០២, ទំព័រទី ៤ ។

[44] កថាខណ្ឌទី ៣១ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ៖ "តួនាទីជាចម្បងរបស់មន្ទីរស-២១ គឺការអនុវត្តន៍ "មាគ៌ានយោបាយបក្ស ចំពោះខ្មាំង" ដែលតាមរយៈមាគ៌ានេះ អ្នកទោស "ត្រូវតែកម្ទេចចោលជាដាច់ខាត" ។

ជំនុំជម្រះ បានរកឃើញថា "តាមរយៈតួនាទី ដែលបានអនុវត្តនៅមន្ទីរស-២១ ឌុច បានដឹងអំពីគោលបំណងនៃមន្ទីរនេះ"[45] ។

៣០. គឺជាការច្បាស់លាស់ណាស់ តាមអង្គហេតុទាំងឡាយដែលបានរកឃើញ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបញ្ជាក់ថា ឌុច បានចូលរួមនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការរបស់មន្ទីរស-២១ ។ អំពើទាំងនេះរាប់បញ្ចូលទាំងការចូលរួមនៅក្នុងកិច្ចប្រជុំដើម្បីបង្កើតមន្ទីរស-២១[46] ការជ្រើសរើសបុគ្គលិកដែលមានបទពិសោធន៍មកពីមន្ទីរសន្តិសុខម-១៣[47] របស់គាត់កាលពីមុនដើម្បីយកមកធ្វើការនៅមន្ទីរស-២១ ការពង្រឹងអនុវត្តនូវវិធានទូទៅនានារបស់បក្សនៅក្នុងមន្ទីរស-២១[48] ការផ្សព្វផ្សាយនូវគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុង "ការកំទេច"ខ្មាំងផ្សេងៗ[49]ការអនុវត្តនូវសិទ្ធិផ្តាច់មុខនៅក្នុងរង្វង់មន្ទីរស-២១ក្នុងការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក ជាមួយមេដឹកនាំជាន់ខ្ពស់នានាលើបញ្ហាសន្តិសុខ[50] និងការដាក់ជូនមេដឹកនាំទាំងនោះនូវការវិភាគរបស់ខ្លួនទៅលើ "ចម្លើយសារភាព" ដែលមានឥទ្ធិពលទៅលើការធ្វើសេចក្តីសម្រេចក្នុងការចាប់ខ្លួនជនសង្ស័យដោយឡែកណាមួយចំនួន[51]។ ការទំនាក់ទំនងទៅវិញទៅមកដោយផ្ទាល់ ជាមួយប្រធានអង្គភាពដទៃៗទៀត អំពីការចាប់ខ្លួនកម្មាភិបាលពីតាមបណ្តាអង្គភាពផ្សេងៗទៀតទាំងនេះ[52]។ ការចូលរួមនៅក្នុងអង្គប្រជុំផ្សេងៗដែលក្នុងពេលនោះ មានការលើកយកមកពិភាក្សាគ្នាអំពីយុទ្ធសាស្ត្រ និងផែនការដើម្បីចាប់ខ្លួន[53] ។ ការ

---

[45] កថាខណ្ឌទី១៣១ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ បន្ថែមលើនេះ ឌុច បានទទួលស្គាល់ថា៖ "ក្នុងតួនាទីរបស់គាត់ជាប្រធានមន្ទីរស-២១ គឺផ្តោតជាសំខាន់ទៅលើការកម្ទេចអ្នក ដែលគេសន្មតថា ជាជនក្បត់បង្កប់ក្នុងជួរបដិវត្តន៍" ។ កថាខណ្ឌទី៣៣៧ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។

[46] *ដូចមុនដដែល*, កថាខណ្ឌ២០ ។

[47] *ដូចមុនដដែល*, កថាខណ្ឌ២១ ។

[48] *ដូចមុនដដែល*, កថាខណ្ឌ២៥ ។

[49] *ដូចមុនដដែល*, កថាខណ្ឌ៤០ ។

[50] *ដូចមុនដដែល*, កថាខណ្ឌ៤២ ។

[51] *ដូចមុនដដែល*, កថាខណ្ឌ៤៣ និង៤៥ ។

[52] *ដូចមុនដដែល*, កថាខណ្ឌ៥៥ ។

[53] *ដូចមុនដដែល*, កថាខណ្ឌ៥៦ ។

បង្រៀនដល់បុគ្គលិកនៃមន្ទីរស-២១ អំពីវិធីសាស្ត្រក្នុងការសួរចម្លើយ និងធ្វើទារុណកម្ម[54] ។ ការធ្វើបាប និងការធ្វើទារុណកម្មអ្នកទោសស-២១ដោយខ្លួនឯងផ្ទាល់[55]។ ការបញ្ជាឱ្យសម្លាប់ដោយផ្ទាល់ និងដោយការធ្វើប្រតិភូកម្មអំណាចទៅឱ្យអ្នកនៅក្រោមបង្គាប់របស់ខ្លួន[56] ។ ការបង្រៀនពីបច្ចេកទេសក្នុងការសម្លាប់[57] និងការទៅទស្សនាទីតាំងវាលពិឃាតជើងឯក[58] ។ អំពើទាំងនេះត្រូវបានកំណត់ថា គឺជាអំពើដែលនាំទៅរកការជួយជម្រុញ "តាមបែបណាមួយដើម្បីធ្វើឱ្យគំរោងផែនការរួមនៅមន្ទីរស-២១ បន្តដំណើរការតទៅមុខទៀត[59] ។

៣១. តាមទម្រង់ "ជាមូលដ្ឋាន" នៃសហកម្មឧក្រិដ្ឋកម្មរួម[60] ចេតនារបស់ ឌុច អាចត្រូវបានទាញចេញជាសេចក្ដីសន្និដ្ឋានពីអំពើរួមបញ្ចូលគ្នាទាំងប៉ុន្មានរបស់គាត់ដែលជួយជម្រុញធ្វើឱ្យគោលបំណងរួមបានបន្តដំណើរការតទៅមុខទៀត ។ លើសពីនេះ ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបានរកឃើញយ៉ាងជាក់លាក់ថា ឌុច "បានមានចេតនាចង់ឱ្យអំពើទាំងប៉ុន្មានរបស់ខ្លួនចូលរួមចំណែកនៅក្នុង" គោលបំណងដ៏ឧក្រិដ្ឋរបស់មន្ទីរស-២១[61] ។ តាមទម្រង់នៃសហកម្មឧក្រិដ្ឋកម្មរួម "ដែលមានលក្ខណៈជាប្រព័ន្ធ"[62] ដែលផ្អែកតាមអង្គហេតុគឺបានបង្ហាញយ៉ាងច្បាស់ថា ឌុច បានដឹងពីប្រព័ន្ធសម្រាប់ធ្វើបាបនៅក្នុងមន្ទីរស-២១ ។ ផ្ទុយទៅវិញ តាមទម្រង់ដែលពង្រីកបន្ថែមនៃសហកម្មឧក្រិដ្ឋកម្មរួម ឧក្រិដ្ឋកម្មទាំងប៉ុន្មានដូចដែលបានបង្ហាញអត្តសញ្ញាណនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ គឺជាផលវិបាកជាលក្ខណៈធម្មជាតិ និងដែលអាចព្យាករណ៍ទុកមុនបាននៃការអនុវត្តគោលបំណងរបស់សហកម្មឧក្រិដ្ឋកម្មរួម ។

---

[54] *ដូចមុនដដែល,* កថាខណ្ឌ៨៣ និង៨៦ ។

[55] *ដូចមុនដដែល,* កថាខណ្ឌ៩០-១០០ ។

[56] *ដូចមុនដដែល,* កថាខណ្ឌ១០៧-១១០ ។

[57] *ដូចមុនដដែល,* កថាខណ្ឌ១១០ ។

[58] *ដូចមុនដដែល,* កថាខណ្ឌ១០៩-១១៣ ។

[59] *ករណីរឿងរបស់ Kvocka,* អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ថ្ងៃទី២៨ កុម្ភៈ ២០០៥ កថាខណ្ឌទី ៨៩ ។

[60] *ករណីរឿងរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច,* ដីកាសន្និដ្ឋានស្ដាពរស្របតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ទាក់ទងនឹង កាំង ហ្គេកអ៊ាវ ហៅ ឌុច, ចុះថ្ងៃទី១៨ កក្កដា ២០០៨, ឯកសារលេខ D96, កថាខណ្ឌទី២៤៥, ២៤៦ និង២៤៧ ។

[61] កថាខណ្ឌទី១៣១ នៃ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។

[62] *ករណីរឿងរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច,* ដីកាសន្និដ្ឋានស្ដាពរស្របតាមវិធាន៦៦ នៃវិធានផ្ទៃក្នុង ទាក់ទងនឹង កាំង ហ្គេកអ៊ាវ ហៅ ឌុច, ចុះថ្ងៃទី១៨ កក្កដា ២០០៨, ឯកសារលេខ D96, កថាខណ្ឌទី២៤៥, ២៤៦ និង២៤៧ ។

៣២. ឌុច បានទទួលរួចហើយនូវសេចក្តីជូនដំណឹងថា នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[63] បានចោទរូបគាត់ថា ជាសហចារីមួយរូបនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម ។ ជាងនេះទៅទៀត នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ការស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត និង នៅក្នុងដីកាដំណោះស្រាយ ទាំងអស់នេះសុទ្ធតែបានជូនដំណឹងឲ្យ ឌុច ដឹងជាបន្តបន្ទាប់អំពី អង្គហេតុទាំងឡាយដែលកំពុងតែស៊ើបសួរ ។ ទោះបីប្រសិនជា ឌុច មិនបានទទួលនូវសេចក្តី ជូនដំណឹងជាផ្លូវការអំពីទម្រង់ពិតប្រាកដនៃសហកម្មឧក្រិដ្ឋកម្មរួម ដែលសហព្រះរាជអាជ្ញា កំពុងតែធ្វើការចោទប្រកាន់រហូតមកទល់នឹងដីកាសន្និដ្ឋានស្ថាពរ ថាសហកម្មឧក្រិដ្ឋកម្មរួម បាន ពឹងផ្អែកយ៉ាងជិតស្និទ្ធលើមូលដ្ឋាននៃអង្គហេតុទាំងឡាយ ដែលបានរៀបរាប់នៅក្នុងដីកា បញ្ជូនរឿងឲ្យស៊ើបសួរក៏ដោយ[64] ក៏វាត្រូវបានស៊ើបសួរ ដោយសហចៅក្រមស៊ើបអង្កេត ហើយដែរ និងដែលបង្កើតបានជាមូលដ្ឋានសម្រាប់ដីកាដំណោះស្រាយទៀតផង ។

៣៣. ឌុច មិនធ្លាប់ត្រូវបានប្រឈមទល់នឹងអង្គហេតុថ្មីៗណាមួយ ដែលសហចៅក្រមស៊ើបអង្កេត មិនបានធ្វើការស៊ើបសួរនោះទេ ។ ហេតុដូចនេះ ការដាក់បន្ថែមនូវសហកម្មឧក្រិដ្ឋកម្មរួមថា ជាទម្រង់នៃការទទួលខុសត្រូវមួយ គឺមិនធ្វើឲ្យខូចប្រយោជន៍ដល់ ឌុច ឬរំលោភទៅលើសិទ្ធិ របស់គាត់ក្នុងការទទួលបាននូវការជូនដំណឹងអំពីអង្គហេតុដែលត្រូវបានធ្វើការស៊ើបសួរ ឬ អំពីឧក្រិដ្ឋកម្មផ្សេងៗដែលរូបគាត់ត្រូវបានចោទប្រកាន់នោះទេ ។ អាស្រ័យហេតុនេះសាលា ដំបូង គួរតែប្រើនូវសិទ្ធិអំណាចរបស់ខ្លួនស្របតាមវិធាន៩៨.២នៃវិធានផ្ទៃក្នុង ដើម្បីកែប្រែការ កំណត់បទចោទនៃអង្គហេតុទាំងឡាយ ដែលបានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយធ្វើការជំនុំជម្រះ ឌុច អំពីបទចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម ។

[63] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ, ចុះថ្ងៃទី១៨ កក្កដា ២០០៨, កថាខណ្ឌទី៨ ។

[64] សហព្រះរាជអាជ្ញា សន្និដ្ឋានថា អង្គហេតុហេតុទាំងឡាយដែលបានរកឃើញនៅក្នុងដីកាដំណោះស្រាយ និងដីកាសន្និដ្ឋានស្ថាពរជាសំខាន់គឺដូចគ្នាទៅនឹងអង្គហេតុទាំងឡាយដែលសហព្រះរាជអាជ្ញាបានចោទប្រកាន់ក្នុងកថាខណ្ឌពីទី៤៩-៥៥ និងពីទី១០៧-១១៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ទោះបីជាដីកាសន្និដ្ឋានស្ថាពរ និងដីកាដំណោះស្រាយមានភាពលំអិតជាងក៏ដោយ ។ ឌុច ត្រូវបានជូនដំណឹងឲ្យដឹងមុនថា អង្គហេតុទាំងនេះកំពុងស្ថិតនៅក្នុងកិច្ចស៊ើបសួរ រួមទាំងអង្គហេតុទាំងឡាយដែលធ្វើឲ្យលេចឡើងនូវសហកម្មឧក្រិដ្ឋកម្មរួមផង ចាប់តាំងពីខែកក្កដា ២០០៧មក ។

៣៤. អង្គបុរេជំនុំជម្រះក៏បានលើកយកបញ្ហាដែលថា សហព្រះរាជអាជ្ញាខកខានមិនបានបង្ហាញនូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមណាមួយ ដែលទាក់ទងទៅនឹងសហកម្មឧក្រិដ្ឋកម្មរួម[65]។ ការបកស្រាយនេះ គឺស្របគ្នាទៅនឹងចរិតលក្ខណៈនៃការស៊ើបសួរនៅក្នុងប្រព័ន្ធច្បាប់របស់កម្ពុជា ។ សហចៅក្រមស៊ើបអង្កេត ត្រូវបានប្ដឹងអំពី "អង្គហេតុទាំងឡាយ" ដែលខ្លួនស៊ើបសួរ[66] មិនមែនអំពីលក្ខណៈសម្បត្តិតាមផ្លូវច្បាប់នោះទេ ហើយសហចៅក្រមស៊ើបអង្កេតក៏មិនមែនត្រូវជាប់កាតព្វកិច្ចក្នុងការអនុវត្តតាមលក្ខណៈសម្បត្តិផ្លូវច្បាប់ ដែលសហព្រះរាជអាជ្ញាបានផ្ដល់ឱ្យនោះដែរ[67] ។

៣៥. អង្គហេតុទាំងឡាយដែលសហចៅក្រមស៊ើបអង្កេត ត្រូវបានប្ដឹងតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺមានលក្ខណៈទូលំទូលាយដើម្បីដាក់បញ្ចូលនូវអង្គហេតុនានាដែលជាដើមអាទិ៍នៃសហកម្មឧក្រិដ្ឋកម្មរួមហើយ[68] ។ អាស្រ័យហេតុនេះ សហកម្មឧក្រិដ្ឋកម្មរួម គឺបានស្ថិតនៅក្នុងវិសាលភាពនៃការស៊ើបសួរជានិច្ច ។ ការតម្រូវឱ្យសហព្រះរាជអាជ្ញាជម្រុញធ្វើតទៅមុខទៀត ជាពិសេសជម្រុញឱ្យកំណត់បទចោទថ្មីៗតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដើម្បីនឹងធ្វើជាលក្ខខណ្ឌតម្រូវជាមុនមួយ សម្រាប់ចោទប្រកាន់ចំពោះជនជាប់ចោទពីបទចោទទាំងនោះ ដោយសារតែអង្គបុរេជំនុំជម្រះហាក់ដូចជាបានឱ្យយោបល់ថាមានការចាំបាច់ គឺវាមុខជានឹងដាក់កម្រិត ដោយគំហុកនិងដោយមិនអាចអនុញ្ញាតឱ្យបានទៅលើសេរីភាពរបស់សហចៅក្រមស៊ើបអង្កេត ក៏ដូចជារបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការបញ្ជាក់ពីលក្ខណៈសម្បត្តិតាមផ្លូវច្បាប់ នៃអង្គហេតុទាំងនោះ ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម កំណត់អំពីវិសាលភាពនៃអង្គហេតុទាំងឡាយដែលត្រូវធ្វើការស៊ើបសួរ ក៏ប៉ុន្តែមិនអាចដាក់កំរិតទៅលើលក្ខណៈ សម្បត្តិតាមផ្លូវច្បាប់ដែលសហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះសាលាដំបូងបានផ្ដល់ឱ្យដល់អង្គហេតុទាំងនោះបានទេ ។

---

[65] សាលដីកាលើបណ្ដឹងឧទ្ធរណ៍, កថាខណ្ឌទី១៣១ ។

[66] វិធាន៥៥.២ នៃវិធានផ្ទៃក្នុង ។

[67] វិធាន៦៧.១ នៃវិធានផ្ទៃក្នុង ។

[68] *សូមអាន* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌទី៤៩-៥៥ និងទី ១០៧-១១៣ ។

## គ. សហកម្មឧក្រិដ្ឋកម្មរួម គឺជាទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌមួយ ដែលអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក

៣៦. ដើម្បីឱ្យ អ.វ.ត.ក អាចយកទម្រង់នៃការទទួលខុសត្រូវណាមួយមកប្រើបាន ត្រូវតែបំពេញឱ្យបានគ្រប់គ្រាន់តាមលក្ខខណ្ឌតម្រូវចំនួន៤ គឺ: (១) ត្រូវតែមានចែងនៅក្នុងច្បាប់ អ.វ.ត.ក ទោះបីជាចែងដោយចំៗ ឬមួយក៏ដោយបង្កប់ន័យក្តី ។ (២) ត្រូវតែមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ។ (៣) ច្បាប់ដែលចែងអំពីបញ្ហានេះ ត្រូវតែផ្តល់សិទ្ធិគ្រប់គ្រាន់ឱ្យចុងចោទអាចប្រើប្រាស់ច្បាប់នេះបានក្នុងពេលវេលាដែលពាក់ព័ន្ធ ។ និង (៤) ចុងចោទទាំងឡាយត្រូវតែអាចមានលទ្ធភាពក្នុងការព្យាករណ៍ទុកជាមុនថា ពួកគេអាចនឹងទទួលខុស ត្រូវខាងព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន[69] ។ សហកម្មឧក្រិដ្ឋកម្មរួមបានបំពេញសព្វគ្រប់តាមលក្ខខណ្ឌតម្រូវនីមួយៗក្នុងចំណោមលក្ខខណ្ឌទាំងនេះ និងគឺជាទម្រង់នៃការទទួលខុសត្រូវមួយ ដែលមានសុពលភាពនៅ អ.វ.ត.ក ។

៣៧. មាត្រា២៩ នៃច្បាប់អ.វ.ត.ក ចែងអំពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គល សម្រាប់ "ជនជាប់សង្ស័យណាម្នាក់ ដែលបានរៀបចំផែនការ ញុះញង់ បញ្ជា ជួយនិងម្រុញ ឬប្រព្រឹត្ត" នូវឧក្រិដ្ឋកម្មទាំងឡាយដែលតុលាការនេះអាចធ្វើការផ្តន្ទាទោសបាន ។ ការប្រព្រឹត្តិបទល្មើសណាមួយតាមរយៈសហកម្មឧក្រិដ្ឋកម្មរួម ត្រូវបានទទួលស្គាល់នៅក្នុងករណីយុត្តិសាស្ត្ររបស់តុលាការ ICTY, ICTR និង SCSL[70]។ ដោយសារតែច្បាប់ អ.វ.ត.ក ត្រូវបានព្រាងឡើងនៅ

---

[69] *ករណីរឿង រដ្ឋអាជ្ញា ទល់នឹង Milutinović* និងគ្នីគ្នាផ្សេងទៀត ដីកាសម្រេចលើញត្តិស្នើសុំរបស់ Dragoljup Odjanić ដែលតវ៉ាជំទាស់អំពីយុត្តាធិការ-សហកម្មឧក្រិដ្ឋកម្មរួម, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY, សំណុំរឿងលេខ: IT-99-37-AR72 ចុះថ្ងៃទី២១ ឧសភា ២០០៣ ត្រង់កថាខណ្ឌទី២១ ("ដីកាសម្រេចក្នុងករណី Milutinović") ។

[70] *ករណីរឿង រដ្ឋអាជ្ញា ទល់នឹង Milutinović* និង អ្នកផ្សេងទៀត ដីកាសម្រេចលើញត្តិស្នើសុំរបស់ Dragoljup Odjanić ដែលតវ៉ាជំទាស់អំពីយុត្តាធិការ-សហកម្មឧក្រិដ្ឋកម្មរួម, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៃតុលាការ ICTY, សំណុំរឿងលេខ IT-99-37-AR72, ចុះថ្ងៃទី២១ ឧសភា ២០០៣ ត្រង់កថាខណ្ឌទី២០ ("បណ្តឹងឧទ្ធរណ៍របស់ លើបញ្ហាសហកម្មឧក្រិដ្ឋកម្មរួម"), អង្គជំនុំជម្រះសាលាឧទ្ធរណ៍... ចាត់ទុកសហកម្មឧក្រិដ្ឋកម្មរួមថាជាទម្រង់នៃ 'ការប្រព្រឹត្តមួយអនុលោមតាមមាត្រា៧.១ នៃលក្ខន្តិកៈ" ។ *ករណីរឿង រដ្ឋអាជ្ញា ទល់នឹង Gacumbitsi,* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR, សំណុំរឿងលេខ ICTR-2001-64-A ចុះថ្ងៃទី៧ កក្កដា ២០០៦ ត្រង់កថាខណ្ឌទី ១៥៨ ។ "អង្គជំនុំជម្រះសាលាឧទ្ធរណ៍ អនុវត្តតាមករណីយុត្តិសាស្ត្ររបស់តុលាការ ICTY គាត់បាន

ក្រោយពីការបង្កើតលក្ខន្តិកៈរបស់តុលាការ ICTY និង ICTR នោះ ដែលក្នុងនោះប្រើពាក្យពេជន៍ស្រដៀងគ្នាយ៉ាងខ្លាំងអំពីទម្រង់នៃការទទួលខុសត្រូវផ្សេងៗនោះហើយ ទើបបានជាពាក្យពេជន៍នៅក្នុងមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក ក៏មានគោលបំណងប្រហាក់ប្រហែលគ្នាដែរ ។

៣៨. ការដាក់បញ្ចូលអំពីសហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងមាត្រា២៩ នៃច្បាប់ អ.វ.ត.ក គឺមានអត្ថន័យមិនឃ្លាតឆ្ងាយពីកម្មវត្ថុ និងគោលបំណងរបស់ច្បាប់ អ.វ.ត.ក ដែលក្នុងមាត្រា១ បានចែងថា "គោលបំណង" នៃច្បាប់នេះ គឺដើម្បីវិនិច្ឆ័យមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មទាំងឡាយ ដែលនៅក្រោមរបបនោះ។ ដើម្បីនឹងធ្វើការវិនិច្ឆ័យទោស "មេដឹកនាំជាន់ខ្ពស់" និង "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ឲ្យបានសម្រេចដោយជោគជ័យ តុលាការនេះត្រូវតែដាក់ការទទួលខុសត្រូវខាងព្រហ្មទណ្ឌទៅលើបុគ្គលដែលជាអ្នកបានបង្កើត និងអ្នកដែលអនុវត្តនូវគោលនយោបាយដ៏ឧក្រិដ្ឋរបស់របបកម្ពុជាប្រជាធិបតេយ្យ គឺមិនមែនគ្រាន់តែទៅលើបុគ្គលជារូបវន្តទាំងឡាយដែលជាអ្នកប្រព្រឹត្តដោយផ្ទាល់ដៃនូវឧក្រិដ្ឋកម្មទាំងឡាយ ដែលជាលទ្ធផលកើតចេញមកពីគោលនយោបាយទាំងនេះទេ ។ សហកម្មឧក្រិដ្ឋកម្មរួម គឺជាទម្រង់នៃការទទួលខុសត្រូវដែលសក្តិសមបំផុតសម្រាប់ភារកិច្ចនេះ[71] ។ ហេតុដូចនេះ ការដាក់បញ្ចូលនូវសហកម្មឧក្រិដ្ឋកម្មរួមធ្វើជាទម្រង់មួយ "នៃការប្រព្រឹត្តិ" គឺស្របគ្នាទៅនឹងគោលបំណងរបស់ច្បាប់ អ.វ.ត.ក និងទៅនឹងចរិតលក្ខណៈរបស់ឧក្រិដ្ឋកម្មអន្តរជាតិ ហើយនិងទៅនឹងរបៀបដែលតុលាការអន្តរជាតិផ្សេងៗទៀត ធ្លាប់បានធ្វើការបកស្រាយដោយពាក្យពេចន៍ដែលដូចគ្នាបេះបិទនៅក្នុងលក្ខន្តិកៈរបស់គេនីមួយរៀងៗខ្លួន ។

---

ទទួលស្គាល់ថាជនជាប់ចោទដែលនៅចំពោះមុខតុលាការនេះ អាចត្រូវទទួលខុសត្រូវជាបុគ្គលចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយ ដែលស្ថិតនៅក្នុងអត្ថន័យនៃមាត្រា៦.១ នៃលក្ខន្តិកៈ នៅក្រោមទម្រង់ណាមួយក្នុងចំណោមទម្រង់នៃការទទួលខុសត្រូវទាំងបី នៃសហកម្មឧក្រិដ្ឋកម្មរួម" ។ *ករណីរឿង រដ្ឋអាជ្ញា ទល់នឹង Fofana និង Kondewa, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ SCSL,* សំណុំរឿងលេខ: SCSL-04-14-T ចុះថ្ងៃទី២ សីហា ២០០៧, ត្រង់កថាខណ្ឌទី២០៨ "(ការប្រព្រឹត្តិ) [ដូចដែលបានប្រើនៅក្នុងលក្ខន្តិកៈ] គឺជាការគ្រប់គ្រាន់ដែលអាចផ្លាស់ប្តូរអត្តចរិត ដូចជាការចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមណាមួយដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្ម" ។

[71] *រដ្ឋអាជ្ញា ទល់នឹង Tadic,* សាលដីកា, សំណុំរឿងលេខ: IT-94-1-T, អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY, ចុះថ្ងៃទី១៥ កក្កដា ១៩៩៩, កថាខណ្ឌទី១៩០ ។

00339251

E73



៣៩. ទម្រង់ទាំងបីនៃសហកម្មឧក្រិដ្ឋកម្មរួម បានចូលជាផ្នែកនៅក្នុងច្បាប់ទម្លាប់អន្តរជាតិតាំងពីយូរយារណាស់មកហើយ មុនឆ្នាំ១៩៧៥-១៩៧៩ ទៅទៀត។ នេះគឺជា ភស្តុតាងជាក់ស្តែងដែលយកមកពីលក្ខន្តិកៈអន្តរជាតិនានាជាច្រើន ពីករណីរឿងក្តី និងពីការប្រកាសសាលក្រមទាំងឡាយដែលមានលក្ខណៈជាផ្លូវការ ដូចជា ពីករណីរឿងក្តីនានាក្នុងស្រុកដែលគាំទ្រចំពោះសហកម្មឧក្រិដ្ឋកម្មរួមដែលមានអត្ថិភាពតាំងពីមុននេះ ។ ទាំងអស់នេះ គឺសុទ្ធតែផ្តល់នូវភស្តុតាងដែលគួរឱ្យជឿបានអំពីទម្លាប់អនុវត្តរបស់រដ្ឋដែលមានលក្ខណៈទូលំទូលាយ និង *កាតព្វកិច្ចតាមផ្លូវច្បាប់* ដែលបង្កើតឡើងនូវច្បាប់ទម្លាប់មអន្តរជាតិ[72] ។ ដោយសារតែសហកម្មឧក្រិដ្ឋរួមគឺជាទម្រង់មួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងអម្លុងពេលនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក នោះ ហេតុដូចនេះ គឺអាចឱ្យធ្វើការព្យាករណ៍ទុកជាមុនបានថា អ្នកចូលរួមទាំងអម្បាលមាណនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម គឺសុទ្ធតែអាចចាប់បង្ខំឱ្យទទួលខុសត្រូវក្រោមទម្រង់នៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងឡាយ ដែលបានប្រព្រឹត្តទាំងនេះ ។

៤០. សហព្រះរាជអាជ្ញា បានដាក់ជូននូវអនុស្សារណៈដ៏ទូលំទូលាយមួយដែលជាផ្នែកនៃសំណុំរឿងលេខ០០២ ដែលពន្យល់អំពីប្រភពដើមនៃសហកម្មឧក្រិដ្ឋកម្មរួម និងអំពីភាពដែលអាចអនុវត្តបានរបស់សហកម្មឧក្រិដ្ឋកម្មរួមនៅចំពោះមុខ អ.វ.ត.ក ។ អនុស្សារណៈនេះមានចំណងជើងថា "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងញត្តិរបស់ អៀង សារី អំពីសហកម្មឧក្រិដ្ឋកម្មរួម" និង "សេចក្តីសង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញា ទៅលើសហកម្មឧក្រិដ្ឋកម្មរួម" និងដែលភ្ជាប់មកជាមួយនេះជា **ឧបសម្ព័ន្ធ ក** ។ នៅក្នុងអនុស្សារណៈទាំងនេះមានអំណះអំណាងគ្រប់គ្រាន់របស់សហព្រះរាជអាជ្ញា ដែលទាក់ទងទៅនឹងភាពអាចអនុវត្តបាននៃសហកម្មឧក្រិដ្ឋកម្មរួមនៅ អ.វ.ត.ក ។

---

[72] តាមនិយមន័យនៃច្បាប់ទំលាប់អន្តរជាតិ *សូមអាន ស្រទាប់ដីដែលលយចេញក្រោមសមុទ្ទនៃអឺរ៉ុបដីគោកទៅសមុទ្ទខាងជើង (ករណីរឿងក្តីរបស់សហព័ន្ធសាធារណៈរដ្ឋអាល្លឺម៉ង់ ទល់នឹងប្រទេសដាណឺម៉ាក ។ ករណីរឿងក្តីរបស់ សហព័ន្ធសាធារណរដ្ឋអាល្លឺម៉ង់ ទល់នឹងប្រទេសហូឡង់),* អង្គសេចក្តី, ចុះថ្ងៃទី២០ កុម្ភៈ ឆ្នាំ១៩៦៩, តុលាការយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ (ICJ) របាយការណ៍ លេខ៣, កថាខណ្ឌទី ៧៧ ។

*សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ*

## ៥. សេចក្ដីសន្និដ្ឋាន

៤១. សហព្រះរាជអាជ្ញា សូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង ប្រើប្រាស់នូវទ្រឹស្ដីច្បាប់ស្ដីពីសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងសាលក្រមរបស់ខ្លួនទាក់ទងនឹងការចូលរួម និងសហប្រតិបត្តិការរបស់ ឌុច នៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមដូចដែលបានគូសបញ្ជាក់ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានស្ថាពរ ហើយនិងនៅក្នុងសារណាលើបណ្ដឹងឧទ្ធរណ៍ ។ សហព្រះរាជអាជ្ញាក៏សូមស្នើផងដែរ សុំឲ្យអង្គជំនុំជម្រះសាលាដំបូងប្រកាសថា ទម្រង់នៃសហកម្មឧក្រិដ្ឋកម្មរួមទាំងបីនេះ គឺអាចអនុវត្តបាននៅ អ.វ.ត.ក ៕

ធ្វើនៅភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៩

សហព្រះរាជអាជ្ញា

CO-PROSECUTORS * CO-PROCUREURS * E.C.C.C

លោកស្រី ជា លាង លោក William SMITH

សហព្រះរាជអាជ្ញា សហព្រះរាជអាជ្ញារង